ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

ឆ្នាំទី ២ លេខ : ៩

# ព្រឹត្តិបត្រព័ត៌មាន

## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

## សកម្មភាព ការងារ

ECOSOCC




កសវ

Work Activities

ប្រចាំខែ កញ្ញា ឆ្នាំ ២០០៩



# មាតិកាអត្ថបទ

**កិច្ចប្រជុំទី២ របស់ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ក្រុមប្រឹក្សាផ្នែកច្បាប់ និងតំណាងអង្គភាពនានានៃរាជរដ្ឋាភិបាល**


| ល.រ | ឈ្មោះអត្ថបទ | |
|---|---|---|
| ១. | សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពី ការបង្កើតគណៈកម្មាធិការជាតិសន្តិសុខលំហសមុទ្រ | ១ |
| ២. | សេចក្តីព្រាងអនុក្រឹត្យស្តីពី នីតិវិធីនៃការចុះបញ្ជីផ្តល់ប័ណ្ណសម្គាល់យានយន្ត និងប្រភេទផ្លាកលេខយាន | ២–៣ |
| ៣. | ប្រជុំឡើងវិញលើសេចក្តីព្រាងព្រះរាជក្រឹត្យស្តីពី ការបង្កើតគណៈឱសថការីកម្ពុជា | ៤ |
| ៤. | សេចក្តីព្រាងអនុក្រឹត្យស្តីពី លក្ខន្តិកៈរបស់សាស្ត្រាចារ្យសម្រាប់ការបណ្តុះបណ្តាលក្នុងវិស័យសុខាភិបាល | ៥–៦ |
| ៥. | កិច្ចប្រជុំបន្តលើសេចក្តីព្រាងអនុក្រឹត្យ ស្តីពីនីតិវិធីវិនិយោគ ការដេញថ្លៃជាសាធារណៈ ឬការជួលតាមការព្រមព្រៀង និងការបង់ថ្លៃឈ្នួលនេសាទ | ៧ |
| ៦. | កិច្ចប្រជុំបន្តលើសេចក្តីព្រាងអនុក្រឹត្យ ស្តីពីលក្ខខណ្ឌ និងបែបបទនៃការធ្វើជំរឿន ការជ្រើសរើស ការអញ្ជើញ ការពន្យារពេលនៃយុវជនកំពុងជាប់ការសិក្សា ប្រជាពលរដ្ឋដែលស្ថិតនៅក្នុងករណីពិសេស និងការអនុវត្តច្បាប់កាតព្វកិច្ចយោធា | ៨ |
| ៧. | សកម្មភាពការងាររបស់ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ | ៩–១៣ |

## ១ សេចក្ដីព្រាងព្រះរាជក្រឹត្យស្ដីពី

# ការបង្កើតគណៈកម្មាធិការជាតិសន្តិសុខលំហសមុទ្រ

កាលពីថ្ងៃទី០១, ០៧ ខែកញ្ញា ឆ្នាំ២០០៩ វេលាម៉ោង ៨:៣០នាទី និងវេលាម៉ោង ១៥:០០នាទី នៅទីស្ដីការគណៈរដ្ឋមន្ត្រី មានបើកអង្គប្រជុំទី១ ក្រោមអធិបតីភាព ឯកឧត្ដម **គីម សយសាម៉ារ៉ៃឡេន** អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ក.វ.ស.) និងលោកជំទាវ **លី ឡូចឡេង** អនុប្រធានសមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាលើ **សេចក្ដីព្រាងព្រះរាជក្រឹត្យស្ដីពីការបង្កើតគណៈកម្មាធិការជាតិសន្តិសុខលំហសមុទ្រ** ដោយមានការអញ្ជើញចូលរួមពីសំណាក់ ឯកឧត្ដមទេសរដ្ឋមន្ត្រី ឱម យិនទៀង ប្រធានលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិប្រឆាំងភេរវកម្ម សមាជិក អគ្គលេខាធិការរង ក.ស.វ. សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល និងមន្ត្រីជំនាញ ទីស្ដីការគណៈរដ្ឋមន្ត្រី។



គណៈកម្មាធិការជាតិប្រឆាំងភេរវកម្មបានស្នើសុំដាក់ឆ្លងនូវសេចក្ដីព្រាងព្រះរាជក្រឹត្យស្ដីពីការបង្កើតគណៈកម្មាធិការជាតិសន្តិសុខលំហសមុទ្រ ដែលបានរៀបចំឡើងដើម្បីធ្វើជាយន្តការថ្នាក់ជាតិនៅក្នុងការដឹកនាំ គ្រប់គ្រង និងពង្រឹងសន្តិសុខសមុទ្រ និងតំបន់ជាប់មាត់សមុទ្រនៃព្រះរាជាណាចក្រកម្ពុជា។

សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានឲ្យបទបញ្ជា (ក្នុងសុន្ទរកថាបើកសិក្ខាសាលាជាតិស្វែងយល់ពីសន្តិសុខលំហសមុទ្រ កាលពីថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០៧) ឲ្យរៀបចំបង្កើតស្ថាប័នថ្នាក់ជាតិមួយដើម្បីទទួលបន្ទុកសន្តិសុខសមុទ្រ។ អស់រយៈពេលជិត ០២ ឆ្នាំកន្លងមក គឺនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ២០០៩ សម្ដេចតេជោនាយករដ្ឋមន្ត្រី បានចេញសេចក្ដីសម្រេចមួយបង្កើតក្រុមការងាររៀបចំយន្តការជាតិទទួលបន្ទុកសន្តិសុខលំហសមុទ្រ ដែលក្នុងនោះតម្រូវឲ្យក្រុមការងារនេះរៀបចំសិក្ខាសាលាថ្នាក់ជាតិជាលើកទី ០២ មួយទៀត និងឲ្យក្រុមការងារនេះរៀបចំសេចក្ដីព្រាងព្រះរាជក្រឹត្យស្ដីពីការបង្កើតគណៈកម្មាធិការជាតិសន្តិសុខលំហសមុទ្រ។

អង្គប្រជុំបានឯកភាពពិនិត្យពិភាក្សាលើសេចក្ដីព្រាងព្រះរាជក្រឹត្យនេះ ហើយបានធ្វើការកែសម្រួលទម្រង់ និងខ្លឹមសារមួយចំនួនដូចជា កែសម្រួលចំណងជើងឲ្យបានខ្លីជាងមុន មាត្រាមួយចំនួនឲ្យមានន័យច្បាស់លាស់ សមាសភាពអនុប្រធាន រក្សាទុកត្រឹម ០៦នាក់ សមាសភាពសមាជិកខ្លះត្រូវផ្លាស់ប្ដូរ និងផ្លាស់ប្ដូរទីតាំងជំពូក និងមាត្រាមួយចំនួន។

អង្គប្រជុំបានបញ្ចប់ការពិភាក្សាលើសេចក្ដីព្រាងព្រះរាជក្រឹត្យនេះ។

សេចក្តីព្រាងអនុក្រឹត្យស្តីពី

# នីតិវិធីនៃការចុះបញ្ជីផ្តល់ប័ណ្ណសម្គាល់យានយន្ត និងប្រភេទផ្លាកលេខយានយន្ត



កាលពីថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០០៩ វេលាម៉ោង ៨:៣០នាទី និងថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០០៩ វេលាម៉ោង ៨:៣០នាទី និងវេលាម៉ោង ១៥:០០នាទី នៅទីស្តីការគណៈរដ្ឋមន្ត្រី មានបើកអង្គប្រជុំទី១ ក្រោមអធិបតីភាព ឯកឧត្តម **ម៉ិច ឈុន** អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ក.វ.ស.) និងឯកឧត្តម **អ៊ឹក ឆ្នារ** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាលើ **សេចក្តីព្រាងអនុក្រឹត្យស្តីពីនីតិវិធីនៃការចុះបញ្ជីផ្តល់ប័ណ្ណសម្គាល់យានយន្ត និងប្រភេទផ្លាកលេខយានយន្ត** ដោយមានការអញ្ជើញចូលរួមពីសំណាក់ តំណាងក្រសួងសាធារណការ និងដឹកជញ្ជូន សមាជិក អគ្គលេខាធិការរង ក.ស.វ. សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល និងមន្ត្រីជំនាញ ទីស្តីការគណៈរដ្ឋមន្ត្រី។

ក្រសួងសាធារណការ និងដឹកជញ្ជូន បានស្នើសុំដាក់ឆ្លងនូវសេចក្តីព្រាងអនុក្រឹត្យស្តីពីនីតិវិធីនៃការចុះបញ្ជីផ្តល់ប័ណ្ណសម្គាល់យានយន្ត និងប្រភេទផ្លាកលេខយានយន្ត ក្នុងគោលបំណង និងមូលហេតុដូចខាងក្រោម៖

១-ច្បាប់ចរាចរណ៍ផ្លូវគោកថ្មីបានចូលជាធរមានធ្វើឲ្យអនុក្រឹត្យ និងលិខិតបទដ្ឋាននានា ដែលបានយោងច្បាប់ចរាចរណ៍ចាស់ ត្រូវទុកជាមោឃៈ។ ដើម្បីបន្តនិរន្តភាពនៃអនុក្រឹត្យទាំងឡាយ ដែលបានអនុម័តរួចកន្លងមក ក្រសួងបានរៀបចំសេចក្តីព្រាងអនុក្រឹត្យនេះ ជំនួសឲ្យអនុក្រឹត្យចំនួន ០២ គឺ ទី១: អនុក្រឹត្យលេខ០៨ អនក្រ ស្តីពីការផ្តល់ប័ណ្ណ សម្គាល់យានយន្តផ្លូវគោក និងទី២: អនុក្រឹត្យលេខ៧៧ អនក្រ ស្តីពីការចេញផ្លាកលេខយានជំនិះ មានន័យថា អនុក្រឹត្យទាំងពីរនេះ កែសម្រួលបញ្ចូលគ្នាជាអនុក្រឹត្យតែមួយ។

២-អនុវត្តអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បានណែនាំឲ្យចុះបញ្ជីផ្តល់ផ្លាកលេខយានយន្តមានលក្ខណៈងាយស្រួល និងឆាប់រហ័ស នៅពេលដែលប្រជាពលរដ្ឋមកទិញយានយន្តពីហាងណាមួយ មានផ្លាកលេខពាក់ស្រាប់តាមចំណង់ចំណូលចិត្តអ្នកទិញ។ ម្ចាស់ហាង ជាអ្នកទទួលខុសត្រូវក្នុងការរៀបចំសំណុំឯកសារ ដើម្បីចុះបញ្ជីផ្តល់ផ្លាកលេខយានយន្តទាំងនោះទៅតាមក្រោយ។

៣-ធ្វើឲ្យម្ចាស់ហាងលក់យានយន្តមានការទទួលខុសត្រូវលើយានយន្តគ្មានពន្ធ ពន្ធក្លែងក្លាយ និងការកោសលុបផ្សេងៗ។

៤-ទៅថ្ងៃអនាគតនឹងមានការខ្វះផ្លាកលេខ ដោយកំណើនយានយន្តកើនឆាប់រហ័ស។

៥-ចាប់ពីឆ្នាំ២០០០ រហូតមកដល់បច្ចុប្បន្ននេះ គ្រោះថ្នាក់ចរាចរណ៍ផ្លូវគោកបានកើនឡើងដោយសារកំណើនយានយន្ត និងប្រជាជនពុំទាន់មានការយល់ដឹងខ្ពស់អំពីសុវត្ថិភាពចរាចរណ៍ផ្លូវគោក ធ្វើឲ្យមានមនុស្សស្លាប់ជាង ០៩នាក់ និងរបួស ៦៩នាក់

ក្នុងមួយថ្ងៃ ដោយសារគ្រោះថ្នាក់ចរាចរណ៍ ហើយធ្វើឲ្យខាតបង់កម្លាំងសកម្មក្នុងសេដ្ឋកិច្ច ២២% ខាតបង់ថវិកាជាតិ ១១៦ លានដុល្លារអាមេរិកក្នុងឆ្នាំ២០០៣ តាមការសិក្សារបស់ធនាគារអភិវឌ្ឍន៍អាស៊ី។ ដោយយក ឆ្នាំ២០០៣ ជាមូលដ្ឋាន ក្រសួងសាធារណការ និងដឹកជញ្ជូន បានប៉ាន់ស្មានការខាតបង់ឡើងដល់ ៣០៨ លានដុល្លារអាមេរិក ក្នុងឆ្នាំ២០០៨ ទាំងនេះពុំទាន់គិតដល់ការបន្សល់ទុកនូវក្មេងកំព្រា ស្ត្រីមេម៉ាយ ជនពិការដែលនឹងរអិលចូលក្នុងភាពក្រីក្រ។





៦-រកវិធីសាស្ត្រផ្តត់ផ្គង់សុវត្ថិភាពចរាចរណ៍ផ្លូវគោក ដោយចាត់ចែងលក់លេខចុះបញ្ជី (លេខហុងស៊ុយ) ដើម្បីប្រមូលថវិកាចូលរដ្ឋ និងចំណាយលើសុវត្ថិភាពចរាចរណ៍ផ្លូវគោក ដែលសព្វថ្ងៃគ្រោះថ្នាក់ចរាចរណ៍មានការកើនឡើងឥតឈប់ឈរ។ បើប្រៀបធៀបនឹងប្រទេសក្នុងតំបន់អាស៊ាន ការចំណាយលើការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោក ប្រទេសកម្ពុជាយើងមានចំនួនតិចតួចណាស់ ពោលគឺ ប្រទេសឡាវ ១៩ លានដុល្លារអាមេរិក ប្រទេសម៉ាឡេស៊ី ៥៥ លានដុល្លាអាមេរិក ប្រទេសថៃ ៥៥ លានដុល្លារអាមេរិក ក្នុងមួយឆ្នាំៗ។ ដូច្នេះការយកថវិកាពីការលក់លេខ "លេខហុងស៊ុយ " ក្រសួងសាធារណការ និងដឹកជញ្ជូន យល់ឃើញថាជាការសមស្រប។

៧-បង្កើតប្រភេទថ្មី ដើម្បីទាក់ទាញអារម្មណ៍ប្រជាជនជាអ្នកមានទ្រព្យធន ចូលចិត្តលេខយានយន្តដែលគេស្រឡាញ់ ចូលចិត្តលេខមានសំណាងល្អ។ គោលបំណងនៃការបង្កើតផ្លាកលេខថ្មី ប្រភេទថ្មី គឺបម្រើសំណូមពររបស់អ្នកមានជីវភាពធូរធារ ដែលគេចង់បានលេខហុងស៊ុយ។

អង្គប្រជុំបានឯកភាពពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យនេះ ហើយបានកែលំអរធ្វើឲ្យអត្ថន័យ និងអត្ថរូបកាន់តែល្អប្រសើរ៕

### ប្រជុំពិភាក្សាឡើងវិញលើសេចក្តីព្រាងព្រះរាជក្រឹត្យស្តីពី

# ការបង្កើតគណៈឱសថការីកម្ពុជា

កាលពីថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០០៩ វេលាម៉ោង ៨:៣០នាទី និងម៉ោង ១៥:០០នាទី និងថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០០៩ វេលាម៉ោង ៨:៣០នាទី នៅទីស្តីការគណៈរដ្ឋមន្ត្រី មានបើកអង្គប្រជុំទី១ ក្រោមអធិបតីភាព ឯកឧត្តម **ឆយ អូន** សមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ក.ស.វ.) និង ឯកឧត្តម **អ៊ុក គុរិ** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាឡើងវិញលើ **សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការបង្កើតគណៈឱសថការីកម្ពុជា** ដោយមានការអញ្ជើញចូលរួមពីសំណាក់ តំណាងក្រសួងសុខាភិបាល សមាជិក អគ្គលេខាធិការរង ក.ស.វ. សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល និងមន្ត្រីជំនាញ ទីស្តីការគណៈរដ្ឋមន្ត្រី។



សេចក្តីព្រាងព្រះរាជក្រឹត្យនេះធ្លាប់បានដាក់ឆ្លងប្រជុំទី១ កាលពីថ្ងៃទី០៩, ១០ ខែមិថុនា ឆ្នាំ២០០៩ ហើយជាលទ្ធផលគឺបានបង្កើតក្រុមការងារចង្អៀតមួយដើម្បីរៀបចំកែសម្រួលឡើងវិញ។



អង្គប្រជុំបានពិភាក្សាគ្នាយ៉ាងតឹងតែង លើបញ្ហាទម្រង់រចនាសម្ព័ន្ធក្នុងជំពូកទី៣ បើធ្វើពីលើចុះក្រោមវាខុសនឹងសេចក្តីជូនដំណឹងរបស់ទីស្តីការគណៈរដ្ឋមន្ត្រី កាលពីឆ្នាំ២០០៥ ដែលណែនាំឲ្យក្រសួងសុខាភិបាលរៀបចំសេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការបង្កើតគណៈឱសថការីកម្ពុជា តាមគំរូព្រះរាជក្រឹត្យស្តីពីការបង្កើតគណៈគ្រូពេទ្យ និងព្រះរាជក្រឹត្យស្តីពី ការបង្កើតគណៈទន្តពេទ្យ ហើយបើធ្វើពីក្រោមឡើងលើតាមទម្រង់នៃព្រះរាជក្រឹត្យទាំងពីរខាងលើ មិនអាចទៅរួច ព្រោះវាជាករណីកូនកើតមុនឪ។

ជាលទ្ធផលអង្គប្រជុំបានសម្រេចដូចខាងក្រោម៖

-សាមីក្រសួងបានរាយការណ៍បញ្ហានេះជូន ឯកឧត្តមរដ្ឋមន្ត្រីក្រសួងសុខាភិបាល។

-រាយការណ៍ពីការលំបាករបស់អង្គប្រជុំនៅពេលនេះជូនឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងស្នើសុំគោលការណ៍ជាមុន ទើបអាចប្រជុំបន្តទៀតបាន។

អង្គប្រជុំបានបញ្ចប់ការពិភាក្សាគ្នានៅមាត្រា១០៕

សេចក្តីព្រាងអនុក្រឹត្យស្តីពី

# លក្ខន្តិកៈរបស់សាស្ត្រាចារ្យសម្រាប់ការបណ្តុះបណ្តាលក្នុងវិស័យសុខាភិបាល

កាលពីថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០០៩ វេលាម៉ោង ៨:៣០ នាទី នៅទីស្តីការគណៈរដ្ឋមន្ត្រី មានបើកអង្គប្រជុំទី១ ក្រោមអធិបតីភាព ឯកឧត្តម **យឹម ឆាយលី** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ក.ស.វ) និង ឯកឧត្តម **សំ សុខផល** អនុប្រធានក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាបន្តលើ**សេចក្តីព្រាងអនុក្រឹត្យស្តីពីលក្ខន្តិកៈរបស់សាស្ត្រាចារ្យសម្រាប់ការបណ្តុះបណ្តាលក្នុងវិស័យសុខាភិបាល** ដោយមានការអញ្ជើញចូលរួមពីសំណាក់ តំណាងក្រសួងសុខាភិបាល សមាជិក អគ្គលេខាធិការរង ក.ស.វ. សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល និងមន្ត្រីជំនាញ ទីស្តីការគណៈរដ្ឋមន្ត្រី។





ក្រសួងសុខាភិបាលបានស្នើសុំឆ្លងសេចក្តីអនុក្រឹត្យស្តីពីលក្ខន្តិកៈរបស់សាស្ត្រាចារ្យសម្រាប់ការបណ្តុះបណ្តាលក្នុងវិស័យសុខាភិបាលដែលក្រសួងបានរៀបចំឡើងក្នុងគោលដៅពង្រឹងគុណភាពបណ្តុះបណ្តាលក្នុងវិស័យសុខាភិបាល តាមរយៈការជ្រើសរើសសាស្ត្រាចារ្យ ប្រកបដោយគុណភាពតាមនិយាមអន្តរជាតិ និងមានគោលបំណងកំណត់ពីលក្ខន្តិកៈ របស់សាស្ត្រាចារ្យរួមមាន លក្ខណៈសម្បត្តិ លក្ខខណ្ឌ សម្រាប់ការជ្រើសរើសការតែងតាំង ព្រមទាំងបន្ទុកការងាររបស់សាស្ត្រាចារ្យគ្រប់កម្រិត សម្រាប់បណ្តុះបណ្តាលក្នុងវិស័យសុខាភិបាល។ លក្ខន្តិកៈរបស់គ្រូណែនាំគ្លីនិក ឬគ្រូកម្មសិក្សា មន្ទីរពេទ្យ និងគ្រូណែនាំអនុវត្ត ឬគ្រូណែនាំអនុវត្ត ឬគ្រូកម្មសិក្សានៅតាមគ្រឹះស្ថានបណ្តុះបណ្តាល ព្រមទាំងគ្រូបង្រៀនទ្រឹស្តី និងសាស្ត្រាចារ្យអញ្ជើញមកពីក្រៅ នឹងត្រូវកំណត់ដាច់ដោយឡែកដោយប្រកាសរបស់ក្រសួងសុខាភិបាល។

ក្រោយពីបានពិភាក្សាផ្លាស់ប្តូរយោបល់គ្នា អង្គប្រជុំបានពិចារណាឃើញថា៖

-ដោយគ្មានមូលដ្ឋានច្បាប់ជាបង្អែកសំរាប់ធ្វើអនុក្រឹត្យនេះ

-ដោយឋានៈជា"សាស្ត្រាចារ្យ" គួរត្រូវបានគ្រប់គ្រងដោយលិខិតបទដ្ឋានគតិយុត្តិ ដើម្បីចៀសវាងការកេងយកចំណេញផ្នែកពាណិជ្ជកម្ម

-ដោយគួរមានគោលការណ៍រួមសំរាប់កំណត់លក្ខណៈវិនិច្ឆ័យនៃបុគ្គលដែលមានឋានៈនិងការទទួលខុសត្រូវផ្នែកអប់រំជាន់ខ្ពស់

-ដោយចង់ឲ្យមានភាពរលូនស៊ីសង្វាក់ជាមួយច្បាប់ស្តីពីការអប់រំ ជាពិសេសមាត្រា៣ និងមាត្រា២០

-ដោយចង់ឲ្យមានភាពស៊ីសង្វាក់ជាមួយគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំកម្ពុជា

-ដោយចង់ឲ្យលិខិតបទដ្ឋានដែលនឹងអនុម័តនេះអាចយកទៅអនុវត្តក្នុងវិស័យផ្សេងទៀតបាន។



អង្គប្រជុំបានស្នើសុំឲ្យក្រសួងសាមីយកបញ្ហានេះទៅពិចារណាឡើងវិញ ដោយសហការជាមួយក្រសួងអប់រំយុវជន និងកីឡា គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំកម្ពុជា ដោយ មានការចូលរួមពីក្រុមប្រឹក្សាអ្នកច្បាប់ និង ECOSOCC ដើម្បីរៀបចំសេចក្តីព្រាង"លិខិតបទដ្ឋានគតិយុត្តិ" ថ្មីមួយ។



ឯកឧត្តម ធា គ្រុយ តំណាងក្រសួងសាមី បានលើកថាគួរឲ្យក្រសួងអប់រំយុវជននិងកីឡា ដើរតួជាប្រធានក្រុមការងារ ដោយមានការចូលរួមសហការជាមួយក្រសួងសុខាភិបាល គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំកម្ពុជា ក្រុមប្រឹក្សាអ្នកច្បាប់ និង ECOSOCC ពីព្រោះក្រសួងអប់រំត្រូវមានការទទួលខុសត្រូវ។

ជាលទ្ធផល អង្គប្រជុំបានឯកភាពថាត្រូវមានក្រុមការងារមួយ ដែលមានសមាសភាព ក្រសួងអប់រំយុវជន និងកីឡា ក្រសួងសុខាភិបាល គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំកម្ពុជា ក្រុមប្រឹក្សាអ្នកច្បាប់ និង ECOSOCC ដើម្បីរៀបចំសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្តិនេះឡើងវិញ៕

កិច្ចប្រជុំពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យស្តីពី

# នីតិវិធីវិនិយោគ ការដេញថ្លៃជាសាធារណៈ ឬ ការជួលតាមការព្រមព្រៀង និងការបង់ថ្លៃឈ្នួលនេសាទ

កាលពីថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៩ វេលាម៉ោង ៨:៣០នាទី និងម៉ោង ១៥:០០នាទី នៅទីស្តីការគណៈរដ្ឋមន្ត្រី មានបើកអង្គប្រជុំទី១ ក្រោមអធិបតីភាព ឯកឧត្តម **សំ សុខផល** អនុប្រធានក្រុមប្រឹក្សាអ្នកច្បាប់ និងឯកឧត្តម **ម៉ិច ឈុន** អនុ–ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធមិ (ក.ស.វ.) ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាបន្តលើ **សេចក្តីព្រាងអនុក្រឹត្យស្តីពី នីតិវិធីវិនិយោគ ការដេញថ្លៃជាសាធារណៈ ឬការជួលតាមការព្រមព្រៀង និងការបង់ថ្លៃឈ្នួលនេសាទ** ដោយមានការអញ្ជើញចូលរួមពីសំណាក់ តំណាងក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ សមាជិក អគ្គលេខាធិការរង ក.ស.វ. សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល និងមន្ត្រីជំនាញ ទីស្តីការគណៈរដ្ឋមន្ត្រី។



## ការកំណត់ទិវាជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់(១)

ការសិក្សាស្រាវជ្រាវបានរកឃើញថា បច្ចុប្បន្នផលសោទបានរួមចំណែកប្រហែល ៧–៨% នៃ GDP ដែលពីមុនធ្លាប់មានប្រហែល ១៣% នៃ GDP ។ ចំណូល ៨០% បានមកពីការសោទទឹកសាប និង ២០% ទៀតបានមកពីសមុទ្រ ដែលជាទូទៅគឺសំរាប់ការនាំចេញ។ ការនេសាទនេះមានផលប៉ះពាល់ដល់ប្រជាជនប្រហែលជាង ០១ លាននាក់ ដែលពាក់ពន្ធ័ ហើយប្រហែល ០៩ សែននាក់ ក្នុងសហគមន៍នេសាទច្រើនជាង ៥០០ នឹងទទួលផលផ្ទាល់ពីអនុក្រឹត្យនេះ។

ការប្រជុំផ្ទៃក្នុងក្រុម២ បានរកឃើញថា នៅពេលដែលអនុក្រឹត្យនេះចូលជាធរមាននឹងមានផលល្អមួយចំនួនះ

ទី១: គឺជួយបង្កើនចំណូលថវិការដ្ឋប្រកបដោយតម្លាភាពពីព្រោះមានការដាក់ឲ្យដេញថ្លៃជាសាធារណៈ។ តាមរយៈនេះអ្នកធ្វើអាជីវកម្មអាចចូលប្រកួតប្រជែង ដោយពុំមានអ្វីផ្ទុយពីគោលការណ៍ប្រកួតប្រជែងនៃទីផ្សារសេរីឡើយ។ ចំណែកឯផលប្រយោ–ជន៍សាធារណៈ ក៏ត្រូវបានការពារតាមរយៈលក្ខខណ្ឌដែលតំរូវឲ្យអ្នកប្រកបអាជីវកម្ម គោរពតាមបទដ្ឋានបច្ចេកទេស។

ទី២: គឺនឹងជួយអភិរក្សនិងអភិវឌ្ឍន៍ធនធានជលផល ព្រោះស្មារតីនៃជំពូក២ និងជំពូក៣ បានរៀបចំយ៉ាងលំអិតអំពីគោលការណ៍នៃការធ្វើអាជិវម្មនិងនីតិវិធីនៃការធ្វើអាជីវកម្ម។ តាមខ្លឹមសារនៃជំពូកទាំងនេះ ប្រភពដែលបង្កើតនិងរក្សាធនធានត្រី នឹងត្រូវបានយកចិត្តទុកដាក់កែលំអ ពោលគឺការតំរូវឲ្យមានអ្នកបច្ចេកទេសនេសាទ ធ្វើសហការជាមួយអ្នកធ្វើអាជីវកម្មទាំងក្នុងការទាញយកផល ទាំងក្នុងការរៀបចំផែនការកែលំអប្រភពបង្កើតនិងរក្សាត្រី ជាចំណុចល្អនៃអត្ថបទនេះ។ ជាលទ្ធផលមានការរំពឹងទុកថា ស្តុកត្រីនឹងកើនឡើង ហើយទីបញ្ចប់ថ្លៃត្រីអាចថយចុះ។

ចំណែកឯចំណុចមិនល្អ គឺ ECOSOCC មានកង្វល់ថារដ្ឋនឹងគ្មានប្រាក់ធានាបណ្តោះអាសន្ននិងប្រាក់ធានាស្ថាពររបស់អ្នកដេញថ្លៃបាន ដើម្បីគ្រប់គ្រងនៅក្នុងដៃ (ចំណុច៦ និង៧ នៃមាត្រា១១) និងដើម្បីបែអូសក្នុងករណីមានកំហុសធ្ងន់ទេ (មាត្រា ៣៨ និង៣៩) ប្រសិនបើនៅពេលអនុវត្តជាក់ស្តែង បែរជាមានការបកស្រាយ ដោយភន្ត័ច្រឡំឲ្យបង់ជាលិខិតធានារបស់ធនាគារ (Bank Guarantee) ជំនួសវិញ ដោយសំអាងថា បើអ្នកដេញថ្លៃអាចសុំបានលិខិតធានាបែបនេះ គេក៏អាចសុំខ្ចីប្រាក់ពីធនាគារមកបង់បានដូចគ្នា៕

(១)ដោយ សមាជិក ក.ស.វ. ក្រុមទី២

## កិច្ចប្រជុំបន្តលើសេចក្តីព្រាងអនុក្រឹត្យស្តីពី

# លក្ខខណ្ឌ និងបែបបទនៃការធ្វើជំរឿន ការជ្រើសរើស ការអញ្ជើញ ការពន្យារពេលនៃយុវជនកំពុងជាប់ការសិក្សា ប្រជាពលរដ្ឋដែលស្ថិតនៅក្នុងករណីពិសេស និងការអនុវត្តច្បាប់កាតពិកិច្ចយោធា

កាលពីថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ ២០០៩ វេលាម៉ោង ៨:៣០ នាទី និងម៉ោង ១៥:០០នាទី នៅទីស្តីការគណៈរដ្ឋមន្ត្រី មានបើកអង្គប្រជុំទី១ ក្រោមអធិបតីភាព ឯកឧត្តម **គីម សយសាម៉ាឡៃន** អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ក.ស.វ.) និង ឯកឧត្តម **ជ័យ ឥន្ទតៅរ៉ៃ** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាបន្តលើ **សេចក្តីព្រាងអនុក្រឹត្យស្តីពីលក្ខខណ្ឌ និងបែបបទនៃការធ្វើជំរឿន ការជ្រើសរើស ការអញ្ជើញ ការពន្យារពេលនៃយុវជនកំពុងជាប់ការសិក្សា ប្រជាពលរដ្ឋដែលស្ថិតនៅក្នុងករណីពិសេស និងការអនុវត្តច្បាប់កាតពិកិច្ចយោធា** ដោយមានការអញ្ជើញចូលរួមពីសំណាក់តំណាងក្រសួងការពារជាតិ សមាជិក អគ្គលេខាធិការរង ក.ស.វ. សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល និង មន្ត្រីជំនាញ ទីស្តីការគណៈរដ្ឋមន្ត្រី។



អង្គប្រជុំបានបន្តពិនិត្យ ពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យនេះ ហើយបានធ្វើការកែសម្រួលទម្រង់ និងខ្លឹមសារមួយចំនួនឲ្យកាន់តែសុក្រឹត្យជាងមុន។

អង្គប្រជុំបានបញ្ចប់ការពិភាក្សាលើសេចក្តីព្រាងនេះ៕



# សកម្មភាពដទៃទៀតរបស់ ឯកឧត្តម យឹម ណុលឡា ទេសរដ្ឋមន្ត្រីទទួលបន្ទុកការងារក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែ កញ្ញា ឆ្នាំ ២០០៩

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ០៣.០៩.០៩ | ចូលរួមជាកិត្តិយសក្នុងពិធីជូនព្រះរាជដំណើរដ៏ខ្ពង់ខ្ពស់របស់ **ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់ ព្រះអង្គនឹងយាងតាមព្រះទីនាំងយន្តហោះពិសេស ពីភ្នំពេញទៅសៀមរាប ដើម្បីដង្ហែអមព្រះរាជដំណើរព្រះករុណាព្រះវររាជបិតាជាតិខ្មែរ និងសម្តេចព្រះវររាជបិតាជាតិខ្មែរ ស្តេចនឹងយាងចេញព្រះរាជដំណើរពីខេត្តសៀមរាប ឆ្ពោះទៅកាន់ទីក្រុងប៉េកាំង នៃសាធារណៈរដ្ឋប្រជាមានិតចិន។ |
| ២ | ០៤.០៩.០៩ | ចូលរួមក្នុងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិភាក្សាលើរបៀបវារៈដូចខាងក្រោម៖<br>១–សេចក្តីព្រាងអនុក្រឹត្យស្តីពី ការបង្កើតក្រុមត្រួតពិនិត្យចម្រុះលើបទល្មើសចរាចរណ៍ផ្លូវគោក។<br>២–សេចក្តីព្រាងអនុក្រឹត្យស្តីពី ក្រមសីលធម៌ទន្តពេទ្យ។<br>៣–សេចក្តីព្រាងអនុក្រឹត្យស្តីពី កំណត់ទិវាជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់។<br>៤–បញ្ហាផ្សេងៗ៖ សំណើសុំការយល់ព្រមពីគណៈរដ្ឋមន្ត្រី ដើម្បីសុំសច្ចាប័ន ពីស្ថាប័ននីតិប្បញ្ញត្តិលើ៖<br>៤.១–កិច្ចព្រមព្រៀងវិនិយោគទូលំទូលាយអាស៊ាន។<br>៤.២–កិច្ចព្រមព្រៀងរវាងអាស៊ានជាមួយប្រទេសដៃគូពាណិជ្ជកម្ម រួមមាន៖<br>–កិច្ចព្រមព្រៀងស្តីពី ភាពជាដៃគូសេដ្ឋកិច្ចទូលំទូលាយ រវាងអាស៊ាន និងជប៉ុន<br>–កិច្ចព្រមព្រៀងស្តីពី ពាណិជ្ជកម្ម សេវាកម្ម នៃកិច្ចព្រមព្រៀងក្របខណ្ឌ ស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយរវាងអាស៊ាន និងចិន<br>–កិច្ចព្រមព្រៀងស្តីពី ពាណិជ្ជកម្ម សេវាកម្ម នៃកិច្ចព្រមព្រៀងក្របខណ្ឌ ស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយរវាងអាស៊ាន និងកូរ៉េ។ |
| ៣ | ០៥.០៩.០៩ | ចូលរួមជាកិត្តិយសក្នុងពិធីដង្ហែរត្រៃបិដក និងក្រុងពាលី បុណ្យឆ្លងពុទ្ធាភិសេកព្រះពុទ្ធរូបអង្គធំ និងសមិទ្ធិផលនានា នៅភ្នំជីតាពេជ្រ ភូមិវត្តភ្នំ ឃុំកំពែង ស្រុកគីរីវង់ ខេត្តតាកែវ ក្រោមអធិបតីភាពដ៏ខ្ពស់ខ្ពស់របស់ឯកឧត្តម **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងលោកជំទាវ។ |
| ៤ | ០៧.០៩.០៩ | ចូលរួមជាកិត្តិយសក្នុងពិធីប្រកាសបេក្ខភាពរបស់ព្រះរាជាណាចក្រកម្ពុជា ក្នុងគណៈកម្មាធិការបេតិកភណ្ឌពិភពលោក ក្រោមអធិបតីភាពដ៏ខ្ពស់ខ្ពស់របស់ឯកឧត្តម **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី។ |

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ៥ | ០៩.០៩.០៩ | ចូលរួមជាកិត្តិយសក្នុងពិធីបុណ្យឆ្លងពុទ្ធាភិសេកព្រះពុទ្ធរូបអង្គធំ និងសមិទ្ធិផលនានា នៅភ្នំជីតាពេជ្រ ភូមិវត្តភ្នំ ឃុំកំពែង ស្រុកគីរីវង់ ខេត្តតាកែវ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវ។ |
| ៦ | ១១.០៩.០៩ រសៀល | ប្រជុំជាមួយក្រុមការងារសាងសង់មជ្ឈមណ្ឌលបដិសណ្ឋាកិច្ចភ្ញៀវទេសចរណ៍ (Welcome Centre) ។ |
| ៧ | ១០–១២.០៩.០៩ | ប្រជុំជាមួយក្រុមការងារសាងសង់អគារថ្មីនៃទីស្តីការគណៈរដ្ឋមន្ត្រី និងក្រុមប្រតិភូមកពីប្រទេសចិនផ្នែកគូរប្លង់ ដើម្បីពិនិត្យ និងពិភាក្សាអំពីអគារថ្មីនៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៨ | ១៤, ២៨.០៩.០៩ | ប្រជុំជាមួយក្រុមការងារសាងសង់អគារថ្មីនៃទីស្តីការគណៈរដ្ឋមន្ត្រី និងក្រុមហ៊ុនសំណង់វិស្វកម្មយូណាន ដើម្បីត្រួតពិនិត្យ និងតាមដានការងារក្នុងខែកញ្ញា ឆ្នាំ២០០៩ ស្តីពីការប្រើប្រាស់ ជួសជុល បំពាក់ឧបករណ៍សម្ភារៈបន្ថែម និងការងារផ្សេងៗសម្រាប់អគារថ្មីនៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៩ | ១៧.០៩.០៩ | ចូលរួមជាកិត្តិយសក្នុងពិធីចុះហត្ថលេខាលើគម្រោងស្តារឡើងវិញនូវវិស័យសិប្បកម្មតម្បាញសូត្រជាមួយអង្គការ FAO ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១០ | ២០.០៩.០៩ | ចូលរួមជាកិត្តិយសក្នុងពិធីទទួលព្រះរាជដំណើរដ៏ខ្ពង់ខ្ពស់របស់ ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង **ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់ ព្រះអង្គនឹងយាងធ្វើមាតុភូមិនិវត្តន៍ពីសាធារណៈរដ្ឋប្រជាមានិតចិន តាមព្រះទីនាំងយន្តហោះពិសេសមកព្រះរាជាណាចក្រកម្ពុជាវិញ។ |
| ១១ | ២៣.០៩.០៩ | ចូលរួមជាកិត្តិយសក្នុងពិធីចុះហត្ថលេខាលើវិសោធនកម្មលេខ១ នៃកិច្ចព្រមព្រៀងផ្តល់ជំនួយរវាងរដ្ឋាភិបាលសហរដ្ឋអាមេរិក និងរាជរដ្ឋាភិបាលកម្ពុជា សម្រាប់កម្មវិធី" កំណើនសេដ្ឋកិច្ច " របស់ USAID ជាមួយលោក Flynn Fuller នាយកបេសសកម្ម USAID នៅកម្ពុជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១២ | ២៨.០៩.០៩ ព្រឹក | ចូលរួមជាកិត្តិយសក្នុងពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការអគារ ទីស្តីការក្រសួងទេសចរណ៍ថ្មី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវ។ |
| ១៣ | ៣០.០៩.០៩ | ចូលរួមប្រជុំជាមួយក្រុមហ៊ុនសិប្បកម្មអង្គរ នៅសណ្ឋាគារ Victoria ខេត្តសៀមរាប។ |

# សកម្មភាពផ្សេងៗរបស់ ឯកឧត្តម គីម សយសាម៉ាឡែន អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែ កញ្ញា ឆ្នាំ ២០០៩

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ០៧.០៩.០៩ | ចូលរួមជាកិត្តិយសក្នុងពិធីប្រកាសបេក្ខភាពរបស់ព្រះរាជាណាចក្រកម្ពុជា ក្នុងគណៈកម្មាធិការបេតិកភណ្ឌពិភពលោក ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ២ | ១៧.០៩.០៩ | ចូលរួមជាកិត្តិយសក្នុងពិធីចុះហត្ថលេខាលើគម្រោងស្តារឡើងវិញនូវវិស័យសិប្បកម្មតម្បាញសូត្រ ជាមួយអង្គការ FAO ក្រោមអធិបតីភាពដ៏ខ្ពស់ខ្ពស់របស់ឯកឧត្តម **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៣ | ២៣.០៩.០៩ | ចូលរួមជាកិត្តិយសក្នុងពិធីចុះហត្ថលេខាលើវិសោធនកម្មលេខ១ នៃកិច្ចព្រមព្រៀងផ្តល់ជំនួយរវាងរដ្ឋាភិបាលសហរដ្ឋអាមេរិក និងរាជរដ្ឋាភិបាលកម្ពុជា សម្រាប់កម្មវិធី " កំណើនសេដ្ឋកិច្ច " របស់ USAID ជាមួយលោក Flynn Fuller នាយកបេសសកម្ម USAID នៅកម្ពុជា ក្រោមអធិបតីភាពដ៏ខ្ពស់ខ្ពស់របស់ឯកឧត្តម **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៤ | ៣០.០៩.០៩ | ចូលរួមជាកិត្តិយសក្នុងពិធីសម្ពោធដាក់ឲ្យប្រើប្រាស់បណ្ណាល័យអេឡិចត្រូនិច ឧបត្ថម្ភដោយសមាគមចិនអាស៊ាន តាមរយៈស្ថានទូតនៃសាធារណរដ្ឋប្រជាមានិតចិន ក្រោមអធិបតីភាពដ៏ខ្ពស់ខ្ពស់របស់ ឯកឧត្តម **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងលោកជំទាវ។ |

# សកម្មភាពផ្សេងៗរបស់ ឯកឧត្តម ចន្ទ សំអាង អគ្គលេខាធិការក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែ កញ្ញា ឆ្នាំ ២០០៩

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ០២.០៩.០៩ | ចូលរួមជាកិត្តិយសក្នុងការទទួលជួបជាមួយមូលនិធិសន្តិភាព Sasakawa ដើម្បីពិភាក្សាលើកិច្ចការកំណែទម្រង់រដ្ឋបាលសាធារណៈ ក្រោមអធិបតីភាពដ៏ខ្ពស់ខ្ពស់របស់ឯកឧត្តម **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ២ | ០២.០៩.០៩ | ចូលរួមជាមួយ ឯកឧត្តម **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ក្នុងការអនុញ្ញាតឲ្យ ឯកឧត្តម Yasujiro SUZUKI តំណាងភ្នាក់ងារ JICA ថ្មីនៅកម្ពុជា ចូលជួបសវនាការ និងសម្តែងការគួរសម។ |

# សកម្មភាពផ្សេងទៀតរបស់ ឯកឧត្តម យឹម ណុលសន អនុប្រធាន ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែ កញ្ញា ឆ្នាំ ២០០៩

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ០៧.០៩.០៩ | ចូលរួមជាកិត្តិយសក្នុងពិធីប្រកាសបេក្ខភាពរបស់ព្រះរាជាណាចក្រកម្ពុជា ក្នុងគណៈកម្មាធិការបេតិកភណ្ឌពិភពលោក ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ២ | ០៩.០៩.០៩ | ចូលរួមជាកិត្តិយសក្នុងពិធីបុណ្យឆ្លងពុទ្ធាភិសេកព្រះពុទ្ធរូបអង្គធំ និងសមិទ្ធិផលនានា នៅភ្នំជីតាពេជ្រ ភូមិវត្តភ្នំ ឃុំកំពែង ស្រុកគីរីវង់ ខេត្តតាកែវ ក្រោមអធិបតីភាពដ៏ខ្ពស់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវ។ |
| ៣ | ១០-១២.០៩.០៩ | ប្រជុំជាមួយក្រុមការងារសាងសង់អគារថ្មីនៃទីស្តីការគណៈរដ្ឋមន្ត្រី និងក្រុមប្រតិភូមកពីប្រទេសចិន ផ្នែកគូរប្លង់ ដើម្បីពិនិត្យ និងពិភាក្សាអំពីអគារថ្មីនៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៤ | ១៩, ២៨.០៩.០៩ | ប្រជុំជាមួយក្រុមការងារសាងសង់អគារថ្មីនៃទីស្តីការគណៈរដ្ឋមន្ត្រី និងក្រុមហ៊ុនសំណង់វិស្វកម្មយុណាន ដើម្បីត្រួតពិនិត្យ និងតាមដានការងារក្នុងខែកញ្ញា ឆ្នាំ២០០៩ ស្តីពីការប្រើប្រាស់ ជួសជុល បំពាក់ឧបករណ៍សម្ភារៈបន្ថែម និងការងារផ្សេងៗសម្រាប់អគារថ្មីនៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៥ | ១៧.០៩.០៩ | ចូលរួមជាកិត្តិយសក្នុងពិធីចុះហត្ថលេខាលើគម្រោងស្តារឡើងវិញនូវវិស័យសិប្បកម្មតម្បាញសូត្រ ជាមួយអង្គការ FAO ក្រោមអធិបតីភាពដ៏ខ្ពស់ខ្ពស់របស់ឯកឧត្តម **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៦ | ២៣.០៩.០៩ | ចូលរួមជាកិត្តិយសក្នុងពិធីចុះហត្ថលេខាលើវិសោធនកម្មលេខ១ នៃកិច្ចព្រមព្រៀងផ្តល់ជំនួយរវាងរដ្ឋាភិបាលសហរដ្ឋអាមេរិក និងរាជរដ្ឋាភិបាលកម្ពុជា សម្រាប់កម្មវិធី " កំណើនសេដ្ឋកិច្ច " របស់ USAID ជាមួយលោក Flynn Fuller នាយកបេសសកម្ម USAID នៅកម្ពុជា ក្រោមអធិបតីភាពដ៏ខ្ពស់ខ្ពស់របស់ឯកឧត្តម **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី។ |

# សកម្មភាពផ្សេងៗទៀតរបស់ ឯកឧត្តម សមាជិក
# ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែ កញ្ញា ឆ្នាំ ២០០៩

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ០១.០៩.០៩ | ឯកឧត្តម **ញឹម បូង៉ាន** ចូលរួមប្រជុំអន្តរក្រសួងដើម្បីពិភាក្សាឡើងវិញលើសេចក្តីព្រាងអនុក្រឹត្យស្តីពីការបោះពុម្ពសារព្រមានសុខភាពលើកញ្ចប់បារី។ |
| ២ | ០២.០៩.០៩ | ឯកឧត្តម **ពេជ កែវ** និងឯកឧត្តម **ឡេង ស្រេង** ចូលរួមប្រជុំអន្តរក្រសួងចង្អៀត ដើម្បីពិភាក្សាលើសំណើសុំអនុញ្ញាតកែសម្រួលមាត្រា ៤ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៥០៤/០៧០ ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០០៤ ស្តីពីការកំណត់រមនីយដ្ឋានប្រាសាទកោះកែរ។ |
| ៣ | ០២, ០៣, ០៨.០៩.០៩ | ឯកឧត្តម **ញឹម បូង៉ាន** ចូលរួមប្រជុំអន្តរក្រសួងដើម្បីពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យស្តីពី ការចាត់ថ្នាក់ និងការដាក់ស្លាកសញ្ញាសារធាតុគីមី។ |
| ៤ | ០៤.០៩.០៩ | ឯកឧត្តម **ញឹម បូង៉ាន** ចូលរួមជាកិត្តិយសក្នុងពិធីដង្ហែរត្រៃបិដក និងក្រុងពាលី បុណ្យឆ្លងពុទ្ធាពិសេកព្រះពុទ្ធរូបអង្គធំ និងសមិទ្ធិផលនានា នៅភ្នំជីតាពេជ្រ ភូមិវត្តភ្នំ ឃុំកំពែង ស្រុកគីរីវង់ ខេត្តតាកែវ។ |
| ៥ | ០៧.០៩.០៩ | ឯកឧត្តម **ញឹម បូង៉ាន** និងឯកឧត្តម **ឡេង ស្រេង** ចូលរួមជាកិត្តិយសក្នុងពិធីប្រកាសបេក្ខភាពរបស់ព្រះរាជាណាចក្រកម្ពុជា ក្នុងគណៈកម្មាធិការបេតិកភណ្ឌពិភពលោក ។ |
| ៦ | ០៩.០៩.០៩ | ឯកឧត្តម **ញឹម បូង៉ាន** ចូលរួមជាកិត្តិយសក្នុងពិធីបុណ្យឆ្លងពុទ្ធាពិសេកព្រះពុទ្ធរូបអង្គធំ និងសមិទ្ធិផលនានា នៅភ្នំជីតាពេជ្រ ភូមិវត្តភ្នំ ឃុំកំពែង ស្រុកគីរីវង់ ខេត្តតាកែវ ក្រោមអធិបតីភាពដ៏ខ្ពស់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវ។ |
| ៧ | ១១.០៩.០៩ | ឯកឧត្តម **ឡេង ស្រេង** ចូលរួមក្នុងពិធីចុះហត្ថលេខាលើគម្រោងស្តារឡើងវិញនូវវិស័យសិប្បកម្មតម្បាញសូត្រ។ |
| ៨ | ១៦.០៩.០៩ | ឯកឧត្តម **អ៊ុំ កុសល** ការអភិវឌ្ឍវិស័យស្រូវ–អង្ករ នៅកម្ពុជាដោយ JICA នៅសណ្ឋាគារសាន់វេ។ |
| ៩ | ១៧.០៩.០៩ | ឯកឧត្តម **ញឹម បូង៉ាន** ចូលរួមជាកិត្តិយសក្នុងពិធីចុះហត្ថលេខាលើគម្រោងស្តារឡើងវិញនូវវិស័យសិប្បកម្មតម្បាញសូត្រ ជាមួយអង្គការ FAO ។ |
| ១០ | ២៣.០៩.០៩ | ឯកឧត្តម **ឡេង ស្រេង** ចូលរួមជាកិត្តិយសក្នុងពិធីចុះហត្ថលេខាលើវិសោធនកម្មលេខ១ នៃកិច្ចព្រមព្រៀងផ្តល់ជំនួយរវាងរដ្ឋាភិបាលសហរដ្ឋអាមេរិក និងរាជរដ្ឋាភិបាលកម្ពុជា សម្រាប់កម្មវិធី" កំណើនសេដ្ឋកិច្ច " របស់ USAID ជាមួយលោក Flynn Fuller នាយកបេសសកម្ម USAID នៅកម្ពុជា។ |
| ១១ | ៣០.០៩.០៩ | ឯកឧត្តម **ញឹម បូង៉ាន** និងឯកឧត្តម **ឡេង ស្រេង** ចូលរួមជាកិត្តិយសក្នុងពិធីសម្ពោធដាក់ឲ្យប្រើប្រាស់បណ្ណាល័យអេឡិចត្រូនិច ឧបត្ថម្ភដោយសមាគមចិនអាស៊ាន តាមរយៈស្ថានទូតនៃសាធារណរដ្ឋប្រជាមានិតចិន។ |

# ព្រឹត្តិបត្រព័ត៌មាន

naykRKbRKgTeTA 3 ឯកឧត្តម គឹម សយសាមរ៉ាឡែន SmaCk k›s›v›
nBnnayk 3 ឯកឧត្តម ទេស្ស សំអាង GKe l xaFkar k›s›v›
nBnGtbT ngcatEcgTeTA 3 ឯកឧត្តម អេង វុត្ថមុនី GKe l xaFkarrg k›s›v›
TnakTng nge)aHBmpSay 3 លោក ម៉ក់ ឆារ៉ា CnykareTsrdm®nTT l bnkkargar k›s›v›
beckeTskBüTr 3 លោក សយ ទាស្លា RbFankarya l y k›s›v›
ykBtman ngrbft 3 លោក ហេង សុភ:បញ្ញា RbFankarya l y k›s›v›



## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌


ទូរស័ព្ទ ០២៣ ២១១ ៩៤៣ , ០១៦ ៣០៧ ៣៣០

ទូរសារ ០២៣ ២១១ ៩៤៣

E-mail: veasna@live.in